# កិច្ចព្រមព្រៀង
# រវាង
# រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
# និង
# រដ្ឋាភិបាលនៃសហព័ន្ធរុស្ស៊ី
# ស្តីពី
# ការជំរុញ និង ការការពារទៅវិញទៅមកនៃវិនិយោគ

រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសហព័ន្ធរុស្ស៊ី (ចាប់ពីពេលនេះតទៅហៅថា "ភាគីជាប់កិច្ចសន្យា")

ក្នុងស្មារតីបង្កើតនូវលក្ខខណ្ឌអនុគ្រោះសម្រាប់ការវិនិយោគដោយអ្នកវិនិយោគរបស់ភាគីជាប់កិច្ចសន្យាម្ខាងនៅលើទឹកដីនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត

ដោយទទួលស្គាល់ថា ការជម្រុញ និងការការពារ ទៅវិញទៅមកនូវការវិនិយោគដោយយកកិច្ចព្រមព្រៀងនេះជាមូលដ្ឋាននឹងនាំមកនូវលំហូរទុន និងរួមចំណែក ក្នុងការអភិវឌ្ឍដើម្បីផលចំណេញផ្នែកពាណិជ្ជកម្ម និងកិច្ចសហប្រតិបត្តិការគ្នាខាងផ្នែកសេដ្ឋកិច្ច វិទ្យាសាស្ត្រ និងបច្ចេកទេស ។

បានព្រមព្រៀងគ្នាដូចតទៅ :

## មាត្រា ១
## និយមន័យ

ចំពោះគោលបំណងនៃកិច្ចព្រមព្រៀងនេះ :

១- ពាក្យ "**អ្នកវិនិយោគ**" (ភាគីជាប់កិច្ចសន្យានីមួយៗ) មានន័យថា:

ក- រូបវ័ន្តបុគ្គល ជាពលរដ្ឋដើមនៃភាគីជាប់កិច្ចសន្យា

ខ- នីតិបុគ្គល ដែលបង្កើតឡើង ឬបានចូលរួមក្រោមច្បាប់នៃភាគីជាប់កិច្ចសន្យា

២- ពាក្យ "**ការវិនិយោគ**" មានន័យថា ទ្រព្យសម្បត្តិគ្រប់ប្រភេទដែលបានដាក់ឱ្យដំណើរវិនិយោគដោយអ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាណាមួយ នៅលើទឹកដីភាគីជាប់កិច្ចសន្យាមួយទៀត ដោយស្របទៅតាមច្បាប់របស់ភាគីជាប់កិច្ចសន្យា និងជាពិសេស:

ក- ចលនទ្រព្យ និងអចលនទ្រព្យ

ខ- ភាគហ៊ុន ស្តុក និងទម្រង់ផ្សេងៗទៀតនៃការចូលរួមទុននៃស្ថាប័នពាណិជ្ជកម្ម

គ- ការទាមទារប្រាក់ ដែលបានវិនិយោគ ក្នុងគោលបំណងបង្កើតតម្លៃសេដ្ឋកិច្ច ឬការទាមទារក្រោមកិច្ចសន្យាណាមួយដែលមានតម្លៃសេដ្ឋកិច្ចទាក់ទងទៅនឹងការវិនិយោគ

ឃ- សិទ្ធិកម្មសិទ្ធិបញ្ញា (សិទ្ធិចម្លង ប៉ាតង់ គម្រោងប្លង់ឧស្សាហកម្ម ស្លាកសញ្ញាពាណិជ្ជកម្ម និង ស្លាកសញ្ញាសេវាកម្ម បច្ចេកវិទ្យា ព័ត៌មានដែលមានតម្លៃផ្នែកពាណិជ្ជកម្ម ស្នាដៃយល់ដឹង

ង- សិទ្ធិដែលបានទទួលដោយច្បាប់ ឬតាមរយៈកិច្ចសន្យា ក្នុងការធ្វើសកម្មភាពធុរៈកិច្ចទាក់ទងជាពិសេសទៅនឹងការធ្វើពាណិជ្ជកម្ម ការអភិវឌ្ឍន៍ចម្រាញ់ និងការធ្វើអាជីវកម្មធនធានធម្មជាតិ ។

រាល់ការផ្លាស់ប្តូរទម្រង់វិនិយោគ នឹងមិនធ្វើឱ្យប៉ះពាល់ដល់លក្ខណៈសម្បត្តិនៃការវិនិយោគប្រសិនបើការផ្លាស់ប្តូរនោះមិនបានអនុវត្តផ្ទុយពីបទប្បញ្ញត្តិនៅក្នុងទឹកដីនៃភាគីជាប់កិច្ចសន្យាដែលបានធ្វើការវិនិយោគនោះ ។

៣- ពាក្យ " **ផលិតផល** " មានន័យថា ទ្រព្យសម្បត្តិគ្រប់ប្រភេទដែលបានធ្វើការវិនិយោគ រាប់បញ្ចូលជាពិសេស ប្រាក់ចំណេញ ភាគលាភ ការប្រាក់ អាជ្ញាប័ណ្ណថ្លៃឈ្នួល និងកម្រៃផ្សេងទៀត ។

៤- ពាក្យ " **ទឹកដី** " នៃរដ្ឋជាភាគីជាប់កិច្ចសន្យាមានន័យថា :

ក- ចំពោះព្រះរាជាណាចក្រកម្ពុជា ទឹកដីនៃព្រះរាជាណាចក្រកម្ពុជា រួមទាំងដែនដី ដែនអាកាស ដែនសមុទ្រ រាប់បញ្ចូលទាំងស្រទាប់ដីក្រោមបាតសមុទ្រ និងបាតសមុទ្រ ដែលព្រះរាជាណាចក្រកម្ពុជាមានសិទ្ធិគ្រប់គ្រងអធិបតេយ្យភាព និងកាតព្វកិច្ចគ្រប់គ្រងផ្លូវច្បាប់ ដោយអនុលោមទៅតាមច្បាប់អន្តរជាតិ និងច្បាប់ជាតិ ។

ខ- ចំពោះសហព័ន្ធរុស្ស៊ី ទឹកដីនៃសហព័ន្ធរុស្ស៊ី ដែលមានតំបន់សេដ្ឋកិច្ចពិសេស និង ដែនសមុទ្រដែលបានកំណត់ យោងទៅតាមកតិការសញ្ញាស្តីពីច្បាប់សមុទ្រ (១៩៨២) ។

៥- ពាក្យ " **ច្បាប់ភាគីជាប់កិច្ចសន្យា** " មានន័យថា ច្បាប់ និងបទប្បញ្ញត្តិដទៃទៀតនៃ ព្រះរាជាណាចក្រកម្ពុជា ឬច្បាប់ និងបទប្បញ្ញត្តិដទៃទៀតនៃ សហព័ន្ធរុស្ស៊ី ។

## មាត្រា ២
## ការការពារការវិនិយោគ

១- ភាគីជាប់កិច្ចសន្យានីមួយៗ ត្រូវលើកទឹកចិត្ត ដើម្បីបង្កើតភាពអនុគ្រោះដល់អ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត ក្នុងការធ្វើវិនិយោគនៅក្នុងទឹកដីរបស់ខ្លួន ហើយទទួលស្គាល់ការវិនិយោគនោះ ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិរបស់ខ្លួន ។

២- ភាគីជាប់កិច្ចសន្យានីមួយៗ ដោយអនុលោមទៅតាមច្បាប់របស់ខ្លួន ត្រូវបានផ្តល់នូវកិច្ចការពារពេញលេញដល់ការវិនិយោគរបស់អ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាម្ខាងទៀតដែលបានធ្វើនៅក្នុងទឹកដីរបស់ខ្លួន ។

## មាត្រា ៣
## ប្រព្រឹត្តិកម្មនៃការវិនិយោគ

១- ភាគីជាប់កិច្ចសន្យានីមួយៗ ត្រូវទទួលបាននូវប្រព្រឹត្តកម្មដោយត្រឹមត្រូវ និងស្មើភាពនៃការវិនិយោគដោយអ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាម្ខាង ដែលទាក់ទងទៅនឹងការគ្រប់គ្រង និងការចំណាយនៃការវិនិយោគបែបនេះ ។

២- ប្រព្រឹត្តកម្មដែលមានចែងក្នុងកថាខណ្ឌ១នៃកិច្ចព្រមព្រៀងនេះ មិនត្រូវតិចជាងអ្វីដែលខ្លួនបានផ្តល់ឱ្យទៅអ្នកវិនិយោគរបស់ខ្លួន ឬចំពោះការវិនិយោគរបស់អ្នកវិនិយោគនៃរដ្ឋទីពណាមួយនោះឡើយ ប្រសិនបើប្រព្រឹត្តិកម្ម ក្រោយនោះ មានលក្ខណៈអនុគ្រោះច្រើនចំពោះអ្នកវិនិយោគដែលពាក់ពន្ធ័ ។

៣- ភាគីជាប់កិច្ចសន្យានីមួយៗ ត្រូវមានការបម្រុងទុកនូវសិទ្ធិអនុវត្ត និងផ្តល់ជូននូវការលើកលែងពីប្រព្រឹត្តិកម្មជាតិដែលមានចែងក្នុងកថាខណ្ឌទី២នៃមាត្រានេះដល់អ្នកវិនិយោគបរទេស និងការវិនិយោគរបស់ពួកគេ រាប់បញ្ចូលទាំងការ វិនិយោគឡើងវិញផង ។

៤- ប្រព្រឹត្តិកម្មជាតិអនុគ្រោះបំផុតដែលមានចែងក្នុងកថាខណ្ឌ២នៃកិច្ចព្រមព្រៀងនេះ មិនត្រូវអនុវត្តលើប្រាក់ចំណេញ ដែលភាគីជាប់កិច្ចសន្យានោះ បានផ្តល់ជូន ឬនឹងផ្តល់ជូននាពេលអនាគត :

ក- ភ្ជាប់ជាមួយនឹងការចូលរួមនៅក្នុងតំបន់ពាណិជ្ជកម្មសេរី គយ ឬសហគមន៍សេដ្ឋកិច្ច

ខ- គោលការណ៍គ្រឹះនៃកិច្ចព្រមព្រៀងដើម្បីជៀសវាងការបង់ពន្ធត្រួតគ្នាឬក៏ការចាត់ចែងផ្សេងៗស្តីពីពន្ធ។

គ- កិច្ចព្រមព្រៀងរវាងសហព័ន្ធរុស្សី និងរដ្ឋដទៃទៀត ដែលមានតាំងពីមុនជាផ្នែកមួយនៃសហភាពសង្គមនិយមសូវៀត។

៥- ដោយមិនរារាំងការអនុវត្តបទប្បញ្ញត្តិនៃមាត្រា៤ មាត្រា៥ និងមាត្រា៨នៃកិច្ចព្រមព្រៀងនេះ ភាគីជាប់កិច្ចសន្យានីមួយៗ ត្រូវទទួលបាននូវប្រព្រឹត្តកម្មមិនតិចជាងអ្វីដែលភាគីជាប់កិច្ចសន្យាម្ខាងទៀតឡើយ ដោយអនុលោមទៅតាមកិច្ចព្រមព្រៀងបង្កើតអង្គការពាណិជ្ជកម្មពិភពលោក ហើយត្រូវបានចុះហត្ថលេខាកាលពីថ្ងៃទី ១៥ ខែមេសា ឆ្នាំ១៩៩៤ ដោយរាប់បញ្ចូល ទាំងកាតព្វកិច្ចក្រោមកិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្ម សេវាកម្ម និងថែមទាំងអនុលោមទៅតាមការរៀបចំពហុភាគីនានាចំពោះការចាត់ចែងនូវប្រព្រឹត្តិកម្មនៃការវិនិយោគដែលភាគីជាប់កិច្ចសន្យាទាំងពីរបានចូលរួម។

## មាត្រា ៤
## អស្សាមិករណ៍

១- ការវិនិយោគនៃអ្នកវិនិយោគរបស់ភាគីជាប់កិច្ចសន្យាណាមួយ ដែលបានធ្វើនៅលើទឹកដីនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត មិនត្រូវរងនូវវិធានការនៃការដកហូតធ្វើជាតូបនីយកម្ម ឬទង្វើដែលមានតំលៃស្មើ(តទៅនេះហៅថា អស្សាមិករណ៍) បានឡើយ លើកលែងតែទង្វើនោះ ធ្វើឡើងដើម្បីបម្រើផលប្រយោជន៍សាធារណៈ និងអនុលោមទៅតាមច្បាប់ ដែលភាគីជាប់កិច្ចសន្យានោះបានបង្កើតឡើងដោយគ្មានការរើសអើង និងបានផ្តល់នូវសំណងភ្លាមៗគ្រប់ចំនួន និងមានប្រសិទ្ធភាព។

២- សំណងត្រូវបានគណនាទៅតាមតម្លៃទីផ្សារនៃការវិនិយោគ ដែលបានដកហូតភ្លាមៗ នៅពេលធ្វើអស្សាមិករណ៍ ឬនៅពេលដែលអាស្សាមិករណ៍នោះត្រូវបានដឹងជាសាធារណៈ។ សំណងនោះ ត្រូវបានទូទាត់សងដោយរូបិយវត្ថុដែលអាចប្តូរបានដោយសេរី និងពុំមានការពន្យាពីភាគីជាប់កិច្ចសន្យាណាមួយ ទៅភាគីជាប់កិច្ចសន្យាណាមួយទៀតឡើយ។ ការប្រាក់តាមអត្រាទីផ្សារពាណិជ្ជកម្មដែលមិនទាបជាងអត្រាប្រាក់ដុល្លាសហរដ្ឋអាមេរិកនៃឥណទាន London Interbank Offered

Rate (LIBOR) កំឡុងពេល ០៦ខែ ត្រូវរាប់បញ្ចូលទាំងការប្រាក់ក្នុងកំឡុងពេលចាប់ពីពេលធ្វើអស្សាមិករណ៍រហូតដល់ពេលទូទាត់សំណង ។

## មាត្រា ៥
## សំណងចំពោះការខាតបង់

អ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាម្ខាងដែលបានធ្វើការវិនិយោគរបស់ខ្លួននៅក្នុងទឹកដីនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត ទទួលរងនូវការខាតបង់ដោយសារសង្គ្រាម សង្គ្រាមស៊ីវិល ឬស្ថានភាពផ្សេងៗទៀតដែលស្រដៀងគ្នា នឹងត្រូវទទួលបាននូវប្រព្រឹត្តិកម្មទាក់ទងទៅនឹងស្តារឡើងវិញ ការចេញសង សំណង ឬការទូទាត់ផ្សេងទៀត ដែលមានលក្ខណៈអនុគ្រោះមិនតិចជាងសំណងដែលផ្តល់ដោយភាគីម្ចាស់ផ្ទះ ទៅឱ្យអ្នកវិនិយោគរបស់ខ្លួន ឬអ្នកវិនិយោគនៃរដ្ឋទី៣ ឬនូវវិធានទាំងឡាយណាដែលទាក់ទងទៅនឹងការខូចខាតនោះ ។

## មាត្រា ៦
## ការផ្ទេរនូវការសង

១- ភាគីជាប់កិច្ចសន្យានីមួយៗ ត្រូវធានាចំពោះអ្នកវិនិយោគនៃការវិនិយោគនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត នៅពេលដែលកើតឡើងនូវការបំពេញកាតព្វកិច្ចពន្ធនិងការគោរពទៅតាមច្បាប់ដែលពាក់ព័ន្ធនូវការផ្ទេរដោយសេរីទៅក្រៅប្រទេសដែលពាក់ព័ន្ធទៅនឹងការវិនិយោគរបស់ពួកគេជាពិសេសៈ

ក- ទិន្នផល

ខ- មូលនិធិសម្រាប់ទូទាត់សងប្រាក់កម្ចី និងបំណុល ដែលបានទទួលស្គាល់ដោយភាគីជាប់កិច្ចសន្យាទាំងពីរនៃការវិនិយោគ ក៏ដូចជាកំណើនអត្រាការប្រាក់

គ- ប្រាក់ដែលបានមកពីការលក់មួយផ្នែក ឬការជម្រះបញ្ជីទាំងមូលនៃការវិនិយោគ

ឃ- ការដកហូតដែលមានចែងក្នុងមាត្រា៤ និងមាត្រា៥នៃកិច្ចព្រមព្រៀងនេះ

ង- ប្រាក់ឈ្នួល និងទឹកប្រាក់បង់ថ្លៃឈ្នួលផ្សេងទៀត ដែលទទួលបានពីអ្នកវិនិយោគ និងនីតិបុគ្គលនៃភាគីជាប់កិច្ចសន្យា ផ្តល់សិទ្ធិធ្វើការភ្ជាប់ការងារវិនិយោគនៅ លើទឹកដីនៃភាគីជាប់កិច្ចសន្យាពីមុន។

២-	ការផ្ទេរ ត្រូវបានធ្វើឡើងដោយគ្មានការពន្យាពេលជា រូបិយវត្ថុដែលអាចប្តូរបានដោយសេរីតាមអត្រាប្តូរប្រាក់ដែលអនុវត្តនៅថ្ងៃផ្ទេរ ដោយផ្អែកតាមបទប្បញ្ញត្តិនៃភាគីជាប់កិច្ចសន្យានៅក្នុងទឹកដីនៃភាគីជាប់កិច្ចសន្យាបានធ្វើការវិនិយោគ ។

## មាត្រា ៧
## ឧបាទេសកម្ម

ភាគីជាប់កិច្ចសន្យា ឬភ្នាក់ងារដែលតែងតាំងរបស់ខ្លួនដែលបានធ្វើការទូទាត់ដើម្បីជាសំណងដល់អ្នកវិនិយោគដោយផ្អែកលើការធានាសម្រាប់ហានិភ័យមិនមែនពាណិជ្ជកម្ម ពាក់ព័ន្ធទៅនឹងការវិនិយោគនៅក្នុងទឹកដីនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត ផ្អែកលើឧបាទេសកម្ម ត្រូវទទួលបាននូវការអនុវត្តសិទ្ធិជាអ្នកវិនិយោគស្មើគ្នាដូចចែង ហើយសិទ្ធិទាំងនោះត្រូវបានអនុវត្តដោយផ្អែកលើបទប្បញ្ញត្តិនៃភាគីជាប់កិច្ចសន្យា ។

## មាត្រា ៨
## ដំណោះស្រាយវិវាទ រវាងភាគីជាប់កិច្ចសន្យា និងអ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត

១-	វិវាទរវាងភាគីជាប់កិច្ចសន្យាម្ខាង ជាមួយអ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត ពាក់ព័ន្ធទៅនឹងការវិនិយោគ នៅលើទឹកដីនៃភាគីជាប់កិច្ចសន្យាទី១ រាប់បញ្ចូលទាំង វិវាទនៃការទាក់ទងទៅនឹងទឹកប្រាក់ លក្ខខណ្ឌ និងនីតិវិធីទូទាត់នៃការដកហូត ដោយអនុលោមទៅតាមមាត្រា៤ និងមាត្រា៥ ឬក៏នីតិវិធីនៃការផ្ទេរទូទាត់ ដូចមានចែងក្នុងមាត្រា៦នៃកិច្ចព្រមព្រៀងនេះ ត្រូវបានដោះស្រាយ ប្រសិនបើអាចធ្វើទៅបានដោយការចរចារ ។

២-	ប្រសិនបើវិវាទ មិនអាចដោះស្រាយបានតាមរយៈនៃការចរចារក្នុងរយៈពេល ០៦ (ប្រាំមួយ)ខែ ដែលចាប់ផ្តើមពីថ្ងៃដែលវិវាទត្រូវបានស្នើឡើងស្តីពីវិធីដោះស្រាយតាមរយៈការចរចារ តាមការជ្រើសរើសរបស់ខ្លួន ហើយអ្នកវិនិយោគនោះមានសិទ្ធិបញ្ជូនករណីនោះ ដើម្បីសុំការដោះស្រាយទៅ:

ក-	តុលាការមានសមត្ថកិច្ចនៃភាគីជាប់កិច្ចសន្យានៅលើទឹកដីដែលបានធ្វើការវិនិយោគ ឬ

ខ-	វេទិការមជ្ឈត្តការតាមរូបភាព អែតហុក ( ADHOC) ដោយអនុលោមតាមវិធានមជ្ឈត្តការនៃគណៈកម្មការសហប្រជាជាតិស្តីពីច្បាប់ពាណិជ្ជកម្មអន្តរជាតិ ( UNCITRAL) ឬ

គ- មជ្ឈមណ្ឌលអន្តរជាតិទទួលបន្ទុកដោះស្រាយវិវាទវិនិយោគ ដែលបានបង្កើតឡើងដោយអនុសញ្ញាស្តីពីដោះស្រាយវិវាទវិនិយោគរវាងរដ្ឋ និងជនជាតិនៃរដ្ឋដទៃទៀតដែលបានចុះហត្ថលេខានៅទីក្រុងវ៉ាស៊ីនតោន ឌី.ស៊ី កាលពីថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៦៥ សម្រាប់ករណីភាគីជាប់ កិច្ចសន្យាទាំងពីរជាភាគីនៃអនុសញ្ញានេះឬស្ថិតនៅវិធានបន្ថែមនៃមជ្ឈមណ្ឌលអន្តរជាតិទទួលបន្ទុកដោះស្រាយវិវាទវិនិយោគ ( លើកលែងតែភាគីជាប់កិច្ចសន្យាម្ខាង ឬទាំងពីរ ពុំមែនជាភាគីនៃអនុសញ្ញានេះ) ។

៣- សេចក្តីសម្រេចមជ្ឈត្តការចុងក្រោយនឹងមានអនុភាពទៅលើគូជំលោះនៃភាគីជាប់កិច្ចសន្យាទាំងពីរ ភាគីជាប់កិច្ចសន្យានីមួយៗ ត្រូវអនុវត្តតាមការសម្រេចនេះ ដោយអនុលោមតាមវិធាននៃច្បាប់ ។

## មាត្រា ៩
## ការដោះស្រាយវិវាទ រវាងភាគីជាប់កិច្ចសន្យា

១- វិវាទរវាងភាគីជាប់កិច្ចសន្យាដែលទាក់ទងដល់ការបកស្រាយ ឬការអនុវត្តកិច្ចព្រមព្រៀងនេះ នឹងត្រូវបានដោះស្រាយតាមរយៈការចរចារ ។
ប្រសិនបើវិវាទ មិនអាចដោះស្រាយបានក្នុងរយៈពេល០៦ ( ប្រាំមួយ) ខែទេ ចាប់ពីថ្ងៃនៃការចរចារវិវាទខាងលើនេះ ត្រូវស្នើឡើងដោយភាគីជាប់កិច្ចសន្យាម្ខាងទៅវេទិការមជ្ឈត្តការ ។

២- វេទិការមជ្ឈត្តការនោះ ត្រូវធ្វើឡើងទៅតាអំណាចផ្ទាល់របស់ខ្លួន ហើយភាគីជាប់កិច្ចសន្យានីមួយៗ ត្រូវតែងតាំងសមាជិកម្នាក់នៃអង្គជំនុំជម្រះ ក្នុងរយៈពេល ០២ (ពីរ )ខែនៃការទទួលបាននូវសំណើដើម្បីសុំឱ្យមានមជ្ឈត្តការ ។ បន្ទាប់មកសមាជិកទាំងពីរនេះត្រូវជ្រើសរើសជនជាតិណាម្នាក់នៃតតីយរដ្ឋ ដែលបានការយល់ព្រមពីភាគីជាប់កិច្ចសន្យាទាំងពីរ ដើម្បីធ្វើជា ប្រធាននៃអង្គជំនុំជម្រះ ឱ្យហើយស្រេចក្នុងរយៈពេល ០១ (មួយ) ខែ គិតចាប់ពីថ្ងៃដែល សមាជិកទាំងពីររូបត្រូវបានតែងតាំងរួច ។

៣- ប្រសិនបើក្នុងរយៈពេលដែលបានកំណត់ក្នុងកថាខ័ណ្ឌទី២នៃមាត្រានេះ ការតែងតាំងមិនអាចធ្វើបាន ភាគីជាប់កិច្ចសន្យាណាមួយអវត្តមាននៅក្នុងការយល់ព្រមនេះ ត្រូវអញ្ជើញប្រធានតុលាការយុត្តិធមិអន្តរជាតិ ដើម្បីសុំឱ្យធ្វើការតែងតាំងនេះ ។ ប្រសិនបើ ប្រធានតុលាការយុត្តិធមិអន្តរជាតិជាជនជាតិនៃរដ្ឋភាគីជាប់កិច្ចសន្យាណាមួយ ឬមិនអាចបំពេញមុខងារនេះបានទេ អនុប្រធានប្រធានតុលាការយុត្តិធមិអន្តរជាតិ ត្រូវបានអញ្ជើញដើម្បីធ្វើការតែងតាំងដ៏ចាំបាច់នេះ ។ ប្រសិនបើអនុប្រធាន

តុលាការយុត្តិធម៌អន្តរជាតិ មិនអាចបំពេញមុខងារនេះបានទៀតនោះ សមាជិកនៃតុលាការយុត្តិធម៌អន្តរជាតិដែលមិនមែនជនជាតិនៃភាគីជាប់កិច្ចសន្យាណាមួយនោះ ដែលមានឋានៈខ្ពស់ជាងគេនឹងត្រូវបានអញ្ជើញ ដើម្បីទទួលការតែងតាំងដ៏ចាំបាច់នេះ ។

៤- វេទិការមជ្ឈត្តការត្រូវធ្វើការសម្រេចក្តីទៅតាមរយៈការបោះឆ្នោតយកសំឡេងភាគច្រើន ។ ក្នុងការសម្រេចចុងក្រោយ ភាគីវិវាទនៃជាប់កិច្ចសន្យាទាំងពីរត្រូវតែគោរពតាម ។ ភាគីជាប់កិច្ចសន្យានីមួយៗ ត្រូវទទួលរ៉ាប់រងចេញនូវបន្ទុកចំណាយសម្រាប់អាជ្ញាកណ្តាលរបស់ខ្លួននិងសម្រាប់អ្នកតំណាងស្របច្បាប់របស់ខ្លួននៅក្នុងនីតិវិធីនៃមជ្ឈត្តការ ។ បន្ទុកចំណាយ សម្រាប់ប្រធានអង្គជំនុំជម្រះ និងចំណាយផ្សេងៗទៀត ត្រូវតែជាបន្ទុកស្មើៗគ្នាដែលភាគីជាប់កិច្ចសន្យា ទាំងពីរត្រូវទទួលរ៉ាប់រង ។ ទោះបីជាយ៉ាងណាក៏ដោយអង្គជំនុំជម្រះអាចបង្គាប់អោយភាគីណាម្ខាងបង់បន្ទុកចំណាយច្រើនជាងភាគីម្ខាងទៀតនៅក្នុងសេចក្តីសម្រេចរបស់ខ្លួនហើយសេចក្តីសម្រេចនោះចងភាគីជាប់កិច្ចសន្យាទាំងសងខាង ។ វេទិការមជ្ឈត្តការ ត្រូវបង្កើតនីតិវិធីផ្ទាល់ខ្លួនដោយឯករាជ្យ ។

## មាត្រា ១០

## ការពិគ្រោះយោបល់

ភាគីជាប់កិច្ចសន្យានីមួយៗ អាចលើកសំណើទៅភាគីជាប់កិច្ចសន្យាម្ខាងទៀត ដើម្បីធ្វើការពិគ្រោះយោបល់ ពាក់ព័ន្ធទៅនឹងការបកស្រាយ ឬសំណូមពរនៃកិច្ចព្រមព្រៀងនេះ ។

## មាត្រា ១១

## វិសាលភាពនៃកិច្ចព្រមព្រៀង

កិច្ចព្រមព្រៀងនេះ ត្រូវបានអនុវត្តទៅលើការវិនិយោគទាំងអស់ដែលបានធ្វើឡើងនៅលើទឹកដីនៃភាគីជាប់កិច្ចសន្យាណាមួយលើទឹកដីនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត ដែលបានធ្វើឡើងចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០០៤ ប៉ុន្តែមិនត្រូវបានយកមកអនុវត្តចំពោះវិវាទណាមួយ ពាក់ព័ន្ធនឹងការវិនិយោគដែលបានកើតឡើង ឬការតវ៉ាណា មួយដែលបានដោះស្រាយរួចហើយមុនការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះឡើយ ។

## មាត្រា ១២

## ការចូលជាធរមាន និងថេរវេលានៃកិច្ចព្រមព្រៀង

១- ភាគីជាប់កិច្ចសន្យាម្ខាង ត្រូវជូនដំណឹងទៅភាគីជាប់កិច្ចសន្យាម្ខាងទៀត នូវការបំពេញរួចរាល់ហើយអំពីនីតិវិធីដែលតម្រូវដោយច្បាប់របស់ខ្លួនដើម្បីដាក់ឱ្យកិច្ចព្រមព្រៀងនេះចូលជាធរមាន ។ កិច្ចព្រមព្រៀងនេះត្រូវចូលជាធរមាននៅថ្ងៃដែលភាគីជាប់កិច្ចសន្យាម្ខាងទៀតជូនដំណឹងក្រោយគេ ។

២- កិច្ចព្រមព្រៀងនេះ មានសុពលភាពអនុវត្តរយៈពេល ១៥ (ដប់ប្រាំ) ឆ្នាំ។ ក្រោយផុតរយៈពេលនេះ កិច្ចព្រមព្រៀង ត្រូវបន្តសុពលភាពរហូតដល់ ០៥ (ប្រាំ) ឆ្នាំទៀត លើកលែងតែភាគីជាប់កិច្ចសន្យាម្ខាងបានជូនដំណឹងទៅភាគីជាប់កិច្ចសន្យាម្ខាងទៀតជាលាយលក្ខណ៍អក្សរយ៉ាងតិច ១២(ដប់ពីរ)ខែ មុនពេលផុតកំណត់ រយៈពេលនៃកិច្ចព្រមព្រៀងនេះ។

៣- កិច្ចព្រមព្រៀងនេះ អាចត្រូវបានធ្វើវិសោធនកម្មជាលាយលក្ខណ៍អក្សរ ដោយមានការយល់ព្រមគ្នាទៅវិញទៅមកនៃភាគីជាប់កិច្ចសន្យាទាំងពីរ។ វិសោធនកម្មនឹងចូលជាធរមាន នៅក្រោយពេលភាគីជាប់កិច្ចសន្យានីមួយៗបានជូនដំណឹងទៅភាគីជាប់កិច្ចសន្យាម្ខាងទៀតជាលាយលក្ខណ៍អក្សរអំពីការបំពេញរួចរាល់នូវនីតិវិធីដែលតម្រូវដោយច្បាប់របស់ខ្លួន ដើម្បីដាក់ឱ្យវិសោធនកម្មនៃកិច្ចព្រមព្រៀងនេះចូលជាធរមាន។

៤- ដើម្បីជាប្រយោជន៍ដល់ការវិនិយោគដែលបានធ្វើនៅថ្ងៃបញ្ចប់កិច្ចព្រមព្រៀងនេះ បណ្តាបញ្ញត្តិនៃមាត្រាទាំងអស់នៃកិច្ចព្រមព្រៀងនេះ នឹងត្រូវបន្តស្ថិតនៅជាធរមាន សម្រាប់រយៈពេល ១៥ (ដប់ប្រាំ) ឆ្នាំ ក្រោយថ្ងៃដែលកិច្ចព្រមព្រៀងបានបញ្ចប់។

ធ្វើនៅម៉ូស្គូ ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៥ ជាបីភាសាគឺ ភាសាខ្មែរ ភាសារុស្ស៊ី និងភាសាអង់គ្លេស ដោយអត្ថបទទាំងអស់នេះ មានតម្លៃគតិយុត្តិស្មើៗគ្នា។ ក្នុងករណីមានការបកស្រាយខុសគ្នា អត្ថបទជាជាភាសាអង់គ្លេស នឹងត្រូវយកមកអនុវត្តជាគោល។

| | |
|---|---|
| **តំណាងរាជរដ្ឋាភិបាល** | **តំណាងរដ្ឋាភិបាល** |
| **នៃព្រះរាជាណាចក្រកម្ពុជា** | **នៃសហព័ន្ធរុស្ស៊ី** |